ព្រះគម្ពីរសំរាប់កុមារ
សូមបង្ហាញជូន

# ព្រះបន្ទូលសន្យាចំពោះលោកអប្រាហាំ



និពន្ធដោយ៖ Edward Hughes

ធ្វើការពន្យល់ដោយ៖ Byron Unger; Lazarus
Alastair Paterson

កែសម្រួលដោយ៖ M. Maillot; Tammy S.

បកប្រែដោយ៖ www.christian-translation.com

ផលិតដោយ៖ Bible for Children
www.M1914.org

©2023 Bible for Children, Inc.
អាជ្ញាប័ណ្ណ៖ លោកអ្នកមានសិទ្ធិក្នុងការថតចម្លង ឬបោះពុម្ពរឿងនេះបាន
តែលោកអ្នកមិនអាចយកវាទៅលក់បានទេ។

នៅគ្រាក្រោយពីទឹកជំនន់
មនុស្សនៅលើផែនដីទាំងមូលបាន
រៀបចំគម្រោងការមួយ។



ពួកគេនិយាយភាសាតែមួយ
មានពាក្យសម្ដីតែមួយ។ គេនិយាយគ្នាថា
៖ “តោះយើង នាំគ្នាសង់ក្រុងមួយ
និង ប្រសាទមួយ ដែលមានកំពូលខ្ពស់ដល់មេឃ
ដើម្បីឲ្យមានឈ្មោះល្បី ហើយយើងនឹងមិន
បែកខ្វែកគ្នាទៅពាសពេញលើផែន
ដីឡើយ”។



ព្រះជាម្ចាស់សព្វព្រះហឫទ័យឲ្យ មនុស្សលោកបានទៅរស់នៅបែកខ្ញែក
គ្នាពាសពេញផែនដីដែលព្រះអង្គបានបង្កើត។ ដូច្នេះ
ហើយទ្រង់ក៏បានធ្វើកិច្ចការដ៏ពិសេសមួយ។ រំពេចនោះ
មនុស្សមួយក្រុមនោះក៏ផ្ដើមនិយាយភាសាផ្សេងៗ
ពីគ្នា។ ព្រះជាម្ចាស់បានប្រទានឲ្យមនុស្ស
លោកមានភាសាថ្មីរៀងៗខ្លួន។



អស់អ្នកដែលនិយាយភាសាដូចគ្នាក៏ប្រមូលផ្តុំគ្នានៅដោយឡែក។ ព្រោះតែគេភ័យខ្លាចមនុស្សដទៃទៀតនិយាយ គេ ស្តាប់មិនយល់។ ព្រះជាម្ចាស់បានធ្វើឲ្យមនុស្សបែកខ្ញែកគ្នាទៅរស់នៅពាសពេញលើផែនដីទាំងមូល តាមរបៀបនេះឯង។ ទីក្រុងដែលគេបានសង់ហើយទុកចោលនោះ



មានឈ្មោះថា “បាបិល” មានន័យថា “បំភាន់”។

ជាច្រើនឆ្នាំកន្លងទៅ ព្រះជាម្ចាស់បានត្រាស់ហៅបុរសម្នាក់នៅរស់នៅទី
ក្រុងអ៊ើរ ក្នុងស្រុកខាល់ដេ លោកមានឈ្មោះថា អាប់រ៉ាម។
ព្រះអង្គមានព្រះបន្ទូលទៅ
កាន់លោកថា ៖

“ចូរចាកចេញពីស្រុក
របស់អ្នក
ហើយធ្វើដំណើរទៅស្រុកមួយ
ដែលយើងនឹង
បង្ហាញអ្នក”។



លោកអាប់រ៉ាមបានស្តាប់បង្គាប់តាមការត្រាស់ហៅនោះ។
ព្រះជាម្ចាស់បាននាំលោកចូលទៅរស់នៅក្នុងស្រុកកាណាន។
លោកបាននាំ លោកស្រីសារ៉ាយ និង
លោកឡុតជាក្មួយប្រុសរបស់លោកទៅជាមួយផង។



លោកអាប់រ៉ាម និង លោកឡុត បានក្លាយជាអ្នកមាននៅក្នុង
ស្រុកកាណាននោះ។ ពួកលោកមានហ្វូងសត្វយ៉ាងច្រើន
សន្ធឹកសន្ធាប់។ ស្រុកនោះ
មិនមានលទ្ធភាពឲ្យលោកទាំង
ពីរនៅជាមួយគ្នាបានឡើយ។



ពួកគង្វាលរបស់លោកឡុត និង ពួកគង្វាលរបស់លោកអាប់រ៉ាម
កើតវិវាទនឹងគ្នា។ លោកអាប់រ៉ាម
មានប្រសាសន៍ទៅកាន់លោកឡុតជាក្មួយថា ៖
“សុំកុំឲ្យមានជម្លោះរវាងអ៊ំ និង ក្មួយឡើយ
យើងនឹងបែកផ្លូវគ្នា, ឡុតអើយ!
ចូរក្មួយជ្រើសកន្លែងដែលក្មួយត្រូវទៅរស់នៅមុនអ៊ុំចុះណា”។





លោកឡុត បានជ្រើសរើសទីក្រុងដ៏ល្អដែលមានវាលស្មៅ
មានទឹកគ្រប់កន្លែង ព្រមទាំងមានភូមិ អ្នកស្រុកផង។
មើលទៅទឹកដីដែលលោកឡុតជ្រើសរើសនោះ
គឺស្អាតខ្លាំងណាស់។ ប៉ុន្តែទីក្រុងនោះ
ជាកន្លែងពោរពេញដោយអំពើ
អាក្រក់។



ក្រោយពីលោកឡុតបានចាកចេញទៅ, ព្រះ
ជាម្ចាស់បានមានព្រះបន្ទូលមកកាន់លោក
អាប់រ៉ាម ម្តងទៀតថា ៖ “យើងនឹងប្រគល់
ស្រុកកាណានទាំងមូលឲ្យដល់អ្នកពូជពង្ស
របស់តរៀងទៅ”។

លោកអាប់រ៉ាម និង អ្នកស្រីសារ៉ាយ គ្មានកូនមួយគ្រាប់សោះ។ តើព្រះជាម្ចាស់នឹងសម្រេចតាមព្រះបន្ទូលសន្យារបស់ព្រះអង្គ យ៉ាងដូចម្ដេចទៅ?





ព្រះជាម្ចាស់បានចាត់បុរសបីនាក់ឲ្យទៅជួបលោកអាប់រ៉ាម
នឹង លោកស្រីសារ៉ាយ



បុរស់ទាំងបីនាក់នោះបានមានប្រសាសន៍ថា
៖ “លោកនឹងមានកូនប្រុសមួយក្នុងពេលដ៏ឆាប់ខាប់មុខនេះហើយ”។
លោកស្រីសារ៉ាយ អស់សំណើចពីរឿងនោះ។
លោកស្រីពុំបានជឿលើព្រះបន្ទូលសន្យារបស់ព្រះជាម្ចាស់ទេ។



លោកស្រីមានអាយុកៅសិបឆ្នាំទៅហើយ។
ព្រះជាម្ចាស់បានប្ដូរឈ្មោះលោកអាប់រ៉ាម ទៅជា “អប្រាហាំ” វិញ ដែលមានន័យថា “ឪពុករបស់សាសន៍ជាច្រើន” រីឯលោកស្រីសារ៉ាយវិញ ត្រូវ ហៅថា “សារ៉ា” វិញ ដែលមានន័យថា “ម្ចាស់ក្សត្រិយ” ។



ព្រះជាម្ចាស់ក៏មានព្រះបន្ទូលប្រាប់
លោកអប្រាហាំថា ព្រះអង្គនឹង
បំផ្លាញទីក្រុងក៏អាក្រក់ចំនួនពីរ
ចោល គឺក្រុងសូដូម និង ក្រុងកូម៉ូ
រ៉ា។ លោកឡុតដែលជាក្មួយប្រុស
លោកអប្រាហាំ និង គ្រួសាររបស់
លោក បានរស់នៅក្នុងក្រុងសូដូម។

លោកឡុតបានជឿលើការ
ព្រមានរបស់ព្រះជាម្ចាស់
ប៉ុន្តែកូនប្រសាររបស់មិនព្រម
ចាកចេញពីទីក្រុងសូដូមទេ។
ពិតជាខ្លោចផ្សាមែន! ពួកគេ
មិនព្រមជឿលើព្រះបន្ទូល
របស់ព្រះជាម្ចាស់សោះ។



លោកឡុត និង ភរិយា ព្រមទាំងកូនស្រីទាំង
ពីរបស់លោកប៉ុណ្ណោះ ដែលបានស្ថិតនៅទី
តាំងដ៏មានសុវត្ថិភាព។ ព្រះជាម្ចាស់បាន
ទម្លាក់ភ្លើង និង ស្ពាន់ធ័រពីលើមេឃមកលើទី
ក្រុងដ៏អាក្រក់នោះ។



គួរឲ្យស្តាយណាស់ ភរិយារបស់លោកឡុត
មិនបានស្តាប់បង្គាប់តាមការព្រមានរបស់ព្រះ
ជាម្ចាស់ទេ  គឺនាងបានងាកក្រោយពេលទៅទី
ក្រុង ក្នុងពេលដែលកំពុងតែរត់នោះ។



ស្រាប់នាងបានក្លាយទៅជាបង្គោលអំបិល
ជាមួយរំពេចនៅក្នុងគ្រានោះទៅ។



ព្រះជាម្ចាស់បានធ្វើតាមព្រះ
បន្ទូលសន្យារបស់ព្រះអង្គ
ចំពោះលោកអប្រាហាំ និង
លោកស្រីសារ៉ា
យ៉ាងពិតប្រាកដ។
ពួកគាត់មានកូន
ប្រុសម្នាក់ក្នុងគ្រាដែល
មានវ័យចំណាស់ទៅហើយ
គឺស្របតាមអ្វីដែលព្រះជា
ម្ចាស់បានមានព្រះបន្ទូលមែ
ន។ ពួកគាត់ពិតជាមាន
អំណរសប្បាយយ៉ាងខ្លាំង
បំផុត ចំពោះកំណើតរបស់
អ៊ីសាក់។



ប្រហែលជាលោកអប្រាហាំបានពិចារណាអំពីព្រះបន្ទូលសន្យារបស់ព្រះដែលថា នឹងប្រទានស្រុកកាណានឲ្យលោក និងពូជពង្សរបស់តរៀងទៅ។



ព្រះជាម្ចាស់ រក្សាព្រះ
បន្ទូលសន្យារបស់ព្រះ
អង្គជានិច្ច។ ព្រះអង្គ
សន្យាយ៉ាងណា ព្រះ
អង្គក៏នឹងសម្រេចយ៉ាង
នោះមិនខានឡើយ។



ព្រះបន្ទូលសន្យាចំពោះលោកអប្រាហាំ

រឿងមួយពីព្រះបន្ទូលរបស់ព្រះជាម្ចាស់, ព្រះគម្ពីរ,

អាចរកឃើញនៅក្នុង

លោកុប្បត្តិ ១១-២១

“ការស្វែងយល់ព្រះបន្ទូលរបស់ព្រះអង្គ ធ្វើឲ្យមនុស្សភ្លឺស្វាង
ហើយធ្វើឲ្យអ្នកទន់ទាបមានប្រាជ្ញា។”
ទំនុកតម្កើង 119:130

ចប់

រឿងព្រះគម្ពីរនេះប្រាប់យើងពីព្រះជាម្ចាស់ដ៏អស្ចារ្យរបស់
យើងដែលបានបង្កើតយើងមក ហើយចង់អោយអ្នកស្គាល់ទ្រង់។

ព្រះអង្គជ្រាបថា យើងបានប្រព្រឹត្តអំពើអាក្រក់, ដែលទ្រង់ហៅការទាំងនោះថា
ជា អំពើបាប។ ទោសនៃអំពើបាបគឺសេចក្តីស្លាប់, ប៉ុន្តែព្រះទ្រង់ស្រឡាញ់យើង
ខ្លាំងណាស់ ដល់ម្ល៉េះហើយបានជាទ្រង់បានចាត់ព្រះយេស៊ូដែលជាព្រះរាជបុត្រា
តែមួយរបស់ព្រះអង្គអោយមកសុគតនៅលើឈើឆ្កាង ហើយបង់ថ្លៃនៃទោស
នោះជំនួសយើង។ ព្រះយេស៊ូបានរស់ពីសុគតឡើងវិញ ហើយបានយាងត្រលប់ទៅ
ស្ថានសួគ៌! ប្រសិនបើអ្នកជឿលើព្រះយេស៊ូ ហើយសុំទ្រង់អោយអភ័យទោសចំពោះ
អំពើបាបរបស់អ្នក, ទ្រង់នឹងលើកលែងទោសអោយអ្នក! ទ្រង់នឹងមក ហើយរស់
ក្នុងចិត្តរបស់អ្នកឥឡូវនេះ, ហើយអ្នកនឹងរស់នៅជាមួយទ្រង់ជារៀងរហូត។

ប្រសិនបើអ្នកជឿថានេះជាការពិត, អ្នកត្រូវទូលទៅកាន់ព្រះអង្គថា៖ ឱព្រះយេស៊ូ
ទូលបង្គំជឿហើយថាទ្រង់ជាព្រះ ហើយបានក្លាយជាមនុស្សម្នាក់មកដើម្បីសុគត
ជំនួសអំពើបាបរបស់ទូលបង្គំ, ហើយពេលនេះទ្រង់រស់ពីសុគតឡើងវិញ។ សូម
ទ្រង់យាងចូលក្នុងជីវិតរបស់ទូលបង្គំ ហើយអភ័យទោសចំពោះអំពើបាបរបស់
ទូលបង្គំ ដើម្បីទូលបង្គំអាចមានជីវិតថ្មីនាពេលឥឡូវនេះបាន ហើយថ្ងៃមួយទូល
បង្គំនឹងទៅនៅជាមួយទ្រង់ជារៀងរហូត។ សូមជួយទូលបង្គំអោយគោរពទ្រង់
ហើយរស់នៅសំរាប់ទ្រង់ដូចជាបុត្ររបស់ទ្រង់។ អាម៉ែន។

សូមអានព្រះគម្ពីរ ហើយអធិដ្ឋានទៅព្រះជារៀងរាល់ថ្ងៃ! យូហាន ៣៖១៦